# ឯកឧត្តមទេសរដ្ឋមន្រ្តី ចម ប្រសិទ្ធ ជួបប្រធានក្រុមហ៊ុន

# ផលិតឧបករណ៍ សំភារៈធ្វើពីផ្លាស្ទិកនៃប្រទេសថៃ



នៅរសៀលថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបលោក **Sanan Angubolgul** ប្រធានក្រុមហ៊ុន **Srithai Superware Public Co.Ltd** និងសហការី ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។



លោក **Sanan Angubolgul** ប្រធានក្រុមហ៊ុន **Srithai Superware Public Company Ltd** បានជម្រាបជូនពីគោលបំណងនៃជំនួបពិភាក្សា គឺចង់ពិនិត្យលទ្ធភាពវិនិយោគក្នុងការបង្កើតរោងចក្រផលិតឧបករណ៍ សំភារៈធ្វើផ្លាស្ទិកនៅកម្ពុជា និងចង់ទទួលបានការណែនាំពីឯកឧត្តម ទេសរដ្ឋមន្រ្តី ចម ប្រសិទ្ធ ទាក់ទងនិងគម្រោងវិនិយោគនេះ ។ លោកប្រធានក្រុមហ៊ុនបានបង្ហាញនូវការមើលឃើញពីវឌ្ឍនភាពនៃសេដ្ឋកិច្ចកម្ពុជា ហើយគិតថា គម្រោងវិនិយោគរបស់ក្រុមហ៊ុនលោក និងទទួលបានការស្វាគមន៍ និងគាំទ្រពីអតិថិជននៅកម្ពុជា ពីព្រោះក្រុមហ៊ុននេះ មកដល់បច្ចុប្បន្ន បានបោះទុនវិនិយោគ នៅប្រទេសមួយចំនួន ដូចជាៈ នៅប្រទេសវៀតណាមមានចំនួន០៣ រោងចក្រ នៅទីក្រុងខុសៗគ្នា នៅ ឥណ្ឌូនេ

ស៊ី ចំនួន ០១ រោងចក្រ និង នៅឥណ្ឌាចំនួន០១ រោងចក្រ ។ ផលិតផលរបស់រោងចក្រត្រូវបានផ្គត់ផ្គង់តាមបណ្តាក្រុមហ៊ុនធំៗជាច្រើន ដូចជា ក្រុមហ៊ុន CoCaCoLa , Pepsi និងអតិថិជនជាច្រើនលើពិភពលោក ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងបានជម្រាបជូនពីស្ថានភាពអំណោយផលរបស់កម្ពុជា ដែលទទួលបាននូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ហើយចំណុចជាសំខាន់ផងដែរនោះ គឺកម្ពុជាទទួលបានភាពអនុគ្រោះពាណិជ្ជកម្មពីបណ្តាប្រទេសអភិវឌ្ឍន៍ និងប្រទេសដៃគូជាច្រើន។ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបញ្ជាក់ថា៖ការបង្កើតរោងចក្រមិនគ្រាន់តែជួយបង្កើតទីផ្សារការងារនៅកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែក្រុមហ៊ុនអាចនាំផលិតផលរបស់ខ្លួន ដែលមានតម្រូវការនៅទីផ្សារក្រៅប្រទេស ធ្វើការនាំចេញដោយមិនជាប់ពន្ធ និងមិនជាប់កូតា តាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ដែលកម្ពុជាមាន ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានណែនាំឱ្យតំណាងរោងចក្រខាងលើ ដាក់ពាក្យ ស្នើសុំការវិនិយោគ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា CDC ដើម្បីក្រុមប្រឹក្សានេះ ពិនិត្យ វាយតម្លៃ ពីនីតិសម្បទារបស់ក្រុមហ៊ុន ។ ចំពោះទីតាំងបង្កើតរោងចក្រ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានស្នើឱ្យពិនិត្យលទ្ធភាពនៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ដែលមានការផ្តល់សេវាសាធារណៈ តាមច្រកចេញ ចូលតែមួយ នៅហ្នឹងកន្លែងស្រាប់ ហើយសង្ឃឹមថា៖ក្រុមហ៊ុន ដ៏មានបទពិសោធន៍មួយនេះ នឹងសម្រេចជោគជ័យនូវគម្រោងវិនិយោគរបស់ខ្លួន ជាពិសេសគឺកិច្ចការពារបរិស្ថានបានល្អប្រសើរនៅកម្ពុជា ។

